# ព្រះរាជក្រម

នស/រកម/០៦០៥/០២១

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល ស្តីពីពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់នៅក្នុងមហាអនុតំបន់មេគង្គ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៥ នាសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភា នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាល ពីថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៥ នាសម័យប្រជុំវិសាមញ្ញរបស់ព្រឹទ្ធសភា នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល
## ស្តីពីពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់នៅក្នុងមហាអនុតំបន់មេគង្គ

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល ស្តីពីពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់នៅក្នុងមហាអនុតំបន់មេគង្គ ដែលធ្វើនៅរាជធានីភ្នំពេញ នាថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០២ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

**មាត្រា ៣.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស.០៥០៦.៣២៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**
**ហត្ថលេខា**
**ស៊ុយ សែម**

លេខ ...៥-ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០០៥
អគ្គលេខាធិការរដ្ឋាភិបាល
ឈាវី តាន់

3/3

**មហាអនុតំបន់មេគង្គ**

# កិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល

# ស្តីពី

# ពាណិជ្ជកម្មថាមពលអគ្គិសនីក្នុងមហាអនុតំបន់មេគង្គ

បកប្រែក្រៅផ្លូវការ

# កិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល
# ស្ដីពី
# ពាណិជ្ជកម្មថាមពលអគ្គិសនីក្នុងមហាអនុតំបន់មេគង្គ

## បុព្វបទ

រដ្ឋាភិបាលនៃបណ្ដាប្រទេសក្នុងមហាអនុតំបន់មេគង្គ ( ដែលតទៅហៅកាត់ថា GMS ) រួមមានៈ ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពភូមា ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ( ដែលតទៅ ហៅកាត់ថា បណ្ដាភាគី ) ។

ដោយទទួលស្គាល់ថា សហគ្រាសថាមពលអគ្គិសនីជាតិនៃបណ្ដាប្រទេស GMS កំពុងទទួលបន្ទុកធ្វើអាជីវកម្ម ផ្គត់ផ្គង់អគ្គិសនីក្នុងប្រទេសរៀងៗខ្លួន និងមានបំណងពង្រីកអាជីវកម្ម ដោយអភិវឌ្ឍការតភ្ជាប់រវាងប្រព័ន្ធបណ្ដាញជាតិ របស់ខ្លួនទៅវិញទៅមកព្រមទាំងពង្រីកសមត្ថភាព និងពាណិជ្ជកម្មថាមពលអគ្គិសនី ដើម្បីផ្ដល់ឱកាសច្រើនថែម ទៀតក្នុងការៈ (១)បង្កើនការទុកចិត្តចំពោះការផ្គត់ផ្គង់ (២)សំរបសំរួលការតំឡើង និងកិច្ចប្រតិបត្តិការមធ្យោបាយ ផលិតកម្ម និងប្រព័ន្ធបញ្ជូន (៣)កាត់បន្ថយទុនវិនិយោគ និងថ្លៃដើមប្រតិបត្តិការ និង (៤) បែងចែកផលប្រយោជន៍ ផ្សេងទៀតដែលបានមកពីប្រតិបត្តិការនៃការតភ្ជាប់ប្រព័ន្ធបណ្ដាញរបស់ខ្លួន។

ដោយយល់ឃើញថាបណ្ដាប្រទេសសមាជិក GMS ដែលបានទទួលស្គាល់ផលប្រយោជន៍នៃកិច្ចសហប្រតិបត្តិការ រវាងផ្នែកថាមពលអគ្គិសនីជាតិរបស់ខ្លួន បានរៀបចំបង្កើតវេទិកាថាមពលអគ្គិសនី (Electric Power Forum-EPF) ក្នុងឆ្នាំ ១៩៩៥ និងក្រុមអ្នកជំនាញខាងការតភ្ជាប់ប្រព័ន្ធបណ្ដាញ និងពាណិជ្ជកម្មថាមពលអគ្គិសនី (Experts Group on Power Interconnection and Trade-EGP) ក្នុងឆ្នាំ ១៩៩៨ ដើម្បីសិក្សានិងផ្ដល់អនុសាសន៍លើការធ្វើពាណិជ្ជកម្ម ថាមពលអគ្គិសនីក្នុង GMS ។

ដោយចងចាំថា ក្នុងកិច្ចប្រជុំទី៩ថ្នាក់រដ្ឋមន្ត្រីនៅទីក្រុងម៉ានីលក្នុងខែមករាឆ្នាំ ២០០០ ដែលរដ្ឋមន្ត្រីនៃបណ្ដា ប្រទេស GMS បានអនុម័ត " សេចក្ដីថ្លែងការណ៍គោលនយោបាយ ស្ដីពីការធ្វើពាណិជ្ជកម្មថាមពលអគ្គិសនីក្នុងមហាអនុ តំបន់មេគង្គ " ក្នុងគោលបំណងជំរុញការធ្វើពាណិជ្ជកម្មថាមពលអគ្គិសនីចំពោះកន្លែងមានលក្ខណៈសេដ្ឋកិច្ចល្អ ។ ក្នុង សេចក្ដីថ្លែងការណ៍គោលនយោបាយ រដ្ឋមន្ត្រីនៃបណ្ដាប្រទេស GMS បានឯកភាពថា រដ្ឋាភិបាលណាដែលចង់ឱ្យ ផ្នែកថាមពលអគ្គិសនីរបស់ខ្លួនចូលរួមក្នុងពាណិជ្ជកម្មតំបន់ ត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល ដើម្បី ផ្ដល់ក្របខណ្ឌការងារសម្រាប់អនុវត្តសេចក្ដីថ្លែងការណ៍គោលនយោបាយនេះ ។

ដូច្នេះ តាមរយៈតំណាងរបស់ខ្លួន ដែលត្រូវបានអនុញ្ញាតត្រឹមត្រូវជាហត្ថលេខីនៃកិច្ចព្រមព្រៀងអន្តររដ្ឋា ភិបាលស្ដីពីពាណិជ្ជកម្មថាមពលអគ្គិសនីក្នុងមហាអនុតំបន់មេគង្គ បណ្ដាភាគីព្រមព្រៀងដូចតទៅៈ

បកប្រែក្រៅផ្លូវការ

## មាត្រា ១ : គោលបំណងនៃកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល

១.១ គោលបំណងនៃកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះ គឺអនុវត្តសេចក្តីថ្លែងការណ៍គោលនយោបាយស្តីពីការធ្វើពាណិជ្ជកម្មថាមពលអគ្គិសនី ដែលបានអនុម័តដោយរដ្ឋមន្ត្រីនៃបណ្តាប្រទេស GMS ក្នុងខែ មករា ឆ្នាំ ២០០០ រួមទាំងការបង្កើតក្របខណ្ឌការងារ ដែលបណ្តាភាគីមានផែនការជំរុញពាណិជ្ជកម្មថាមពលអគ្គិសនីក្នុងមហាអនុតំបន់មេគង្គ (GMS) ។ សេចក្តីថ្លែងការគោលនយោបាយត្រូវបានបញ្ចូលជាឧបសម្ព័ន្ធ (ក) នៃកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះ ។

## មាត្រា ២: គោលការណ៍និងទិសដៅពាណិជ្ជកម្មថាមពលអគ្គិសនីក្នុងមហាអនុតំបន់មេគង្គ

២.១ គោលការណ៍និងទិសដៅក្នុងមាត្រានេះ គឺស្របតាមការអនុវត្តទិសដៅនៃសេចក្តីថ្លែងការណ៍គោលនយោបាយស្តីពីការធ្វើពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់ក្នុងមហាអនុតំបន់មេគង្គដូចដែលមានចែងក្នុងឧបសម្ព័ន្ធ (ក) ។

២.២ បណ្តាភាគីយល់ព្រមថា ទំនាក់ទំនងរបស់ខ្លួនត្រូវផ្អែកលើគោលការណ៍ដូចតទៅ :

ក) សហប្រតិបត្តិការ : បញ្ហាទាក់ទងនឹងការតភ្ជាប់នេះត្រូវដោះស្រាយក្នុងស្មារតីសហប្រតិបត្តិការនិងផលប្រយោជន៍ទៅវិញទៅមក បណ្តាភាគីមានសិទ្ធិនិងកាតព្វកិច្ចស្មើគ្នា ធ្វើសកម្មភាពជាសាមគ្គីភាព និងទប់ស្កាត់រាល់ការដណ្តើមយកអត្ថប្រយោជន៍រៀង១ខ្លួន។

ខ) ភាពឈានឡើង : បណ្តាភាគីយកចិត្តទុកដាក់ការអភិវឌ្ឍន៍ជាបន្តបន្ទាប់នៃពាណិជ្ជកម្មអគ្គិសនីតំបន់ និង

គ) ការអភិវឌ្ឍន៍និរន្តភាពជាលក្ខណៈបរិស្ថាន : ពោលគឺពាណិជ្ជកម្មអគ្គិសនីតំបន់ត្រូវបានដំណើរការក្នុងល័ក្ខខ័ណ្ឌមួយនៃការគោរពបរិស្ថាន ។

២.៣ ទិសដៅពាណិជ្ជកម្មថាមពលអគ្គិសនីក្នុងកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលគឺសំរាប់អ្នកចូលរួមទាំងអស់ដើម្បី :

ក) សំរបសំរួល និង សហប្រតិបត្តិការក្នុងការងារផែនការ និងដំណើរការប្រព័ន្ធរបស់ខ្លួន ដើម្បីបន្ថយជាអប្បរមាថ្លៃដើម ដោយធានាបាននូវការទុកចិត្ត និង

ខ) ទូទាត់ថ្លៃដើមរបស់ខ្លួនបានទាំងស្រុង និងបែងចែកដោយសមធម៌ផលចំណេញដែលទទួលបាន ដោយរួមបញ្ចូលទាំងការកាត់បន្ថយសមត្ថភាពផលិតកម្មនិងការបញ្ជូនដែលបានតំរូវការកាត់បន្ថយចំណាយប្រេង និងការប្រើប្រាស់កាន់តែប្រសើរឡើងនៃប្រភពអគ្គិសនីថ្លៃទាប និង

គ) ផ្តល់សេវាកម្មអគ្គិសនីជាទីទុកចិត្ត និងប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចដល់អតិថិជនរបស់ភាគីនីមួយ១។

## មាត្រា៣ : និយមន័យ

៣.១ ឧបសម្ព័ន្ធ (Annex) - ឯកសារភ្ជាប់ជាមួយកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះ ដែលជាផ្នែកសរុបមួយនៃកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះ។

បកប្រែក្រៅផ្លូវការ

៣.២ ទីភ្នាក់ងារបានអនុញ្ញាត (Authorized Agency) - ទីភ្នាក់ងារដែលបានចាត់តាំងដោយបណ្តាភាគីដើម្បីអនុវត្ត កិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះ ។

៣.៣ វេទិកាថាមពលអគ្គិសនី (Electric Power Forum - EPF) - ក្រុមថាមពលអគ្គិសនីដែលបានបង្កើតឡើងអនុលោមតាមកម្មវិធី GMS ក្នុងឆ្នាំ ១៩៩៥ ។

៣.៤ ក្រុមអ្នកជំនាញខាងការតភ្ជាប់ប្រព័ន្ធបណ្តាញ និងពាណិជ្ជកម្មថាមពលអគ្គិសនី (Experts Group on Power Interconnection and Trade - EGP) - ក្រុមអ្នកជំនាញមកពីសហគ្រាសថាមពលអគ្គិសនី និងរដ្ឋាភិបាលសមាជិក GMS និងដែលបានបង្កើតឡើងដោយវេទិការថាមពលអគ្គិសនីក្នុងឆ្នាំ ១៩៩៨ ។

៣.៥ កម្មវិធីនៃមហាអនុតំបន់មេគង្គ (GMS Program) - កម្មវិធីសហប្រតិបត្តិការសេដ្ឋកិច្ចសំរាប់មហាអនុតំបន់មេគង្គ ដែលបានផ្តួចផ្តើមឡើងក្នុងឆ្នាំ ១៩៩២ ។

៣.៦ កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីនៃប្រទេសក្នុងមហាអនុតំបន់មេគង្គ (GMS Ministerial Meeting) - កិច្ចប្រជុំប្រចាំឆ្នាំថ្នាក់រដ្ឋមន្ត្រីនៃប្រទេសក្នុងមហាអនុតំបន់មេគង្គដែលបានរៀបចំជាផ្នែកមួយនៃកម្មវិធីរបស់ GMS ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការអនុតំបន់ និង ផ្តល់ការណែនាំ និង ការគាំទ្រទាំងមូល ។

៣.៧ គណៈកម្មាធិការសម្របសម្រួលពាណិជ្ជកម្មថាមពលអគ្គិសនីក្នុងមហាអនុតំបន់មេគង្គ (Regional Power Trade Coordination Committee-RPTCC)- គណៈកម្មាធិការសម្របសម្រួលពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់បង្កើតឡើងដើម្បីសម្របសម្រួលការអនុវត្តន៍ពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់ស្របតាមកិច្ចព្រមព្រៀងនេះ ។

៣.៨ មហាអនុតំបន់មេគង្គ (Greater Mekong Sub-region) - ព្រះរាជាណាចក្រកម្ពុជា ខេត្តយូណាននៃសាធារណៈរដ្ឋប្រជាមានិតចិន សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហព័ន្ធភូមា ព្រះរាជាណាចក្រថៃ សាធារណៈរដ្ឋសង្គមនិយមវៀតណាម ។

៣.៩ កិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល (Inter-Governmental Agreement) - កិច្ចព្រមព្រៀងនេះរួមជាមួយនឹងឧបសម្ពន្ធ័ក្នុងចំណោមព្រះរាជាណាចក្រកម្ពុជា សាធារណៈរដ្ឋប្រជាមានិតចិន សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហព័ន្ធភូមា ព្រះរាជាណាចក្រថៃ សាធារណៈរដ្ឋសង្គមនិយមវៀតណាម ។

៣.១០ កិច្ចព្រមព្រៀងប្រតិបត្តិការពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់ (Regional Power Trade Operating Agreement PTOA)-ជាកិច្ចព្រមព្រៀងប្រតិបត្តិការពាណិជ្ជកម្ម និង បច្ចេកទេសសំរាប់ការអនុវត្តន៍ និង ប្រតិបត្តិការពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់ ក្នុងកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះដែលនឹងត្រូវព្រាងនៅក្រោមការគ្រប់គ្រងរបស់ (RPTCC)

៣.១១ បណ្តាភាគី (Parties) - រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណៈរដ្ឋប្រជាមានិតចិន សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហព័ន្ធភូមា ព្រះរាជាណាចក្រថៃ សាធារណៈរដ្ឋសង្គមនិយមវៀតណាម ។

បកប្រែក្រៅផ្លូវការ

៣.១២ សេចក្តីថ្លែងការណ៍គោលនយោបាយស្តីពីពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់ក្នុងមហាអនុតំបន់មេគង្គ (Policy Statement on Regional Power Trade in the Greater Mekong Sub-region) - ជាសេចក្តីថ្លែងការណ៍ដែលបានអនុមត័ដោយកិច្ចប្រជុំទី ៩ ថ្នាក់រដ្ឋមន្ត្រី GMS នៅទីក្រុងម៉ានីល ក្នុងខែ មករា ឆ្នាំ ២០០០។

## មាត្រា៤ : ក្របខ័ណ្ឌការងារស្ថាប័ន

៤.១ បណ្តាភាគីត្រូវផ្ទេរការទទួលខុសត្រូវលើការដឹកនាំ និងពិនិត្យតាមដាននៃការធ្វើពាណិជ្ជកម្មតំបន់តាមកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះ ទៅឱ្យរដ្ឋមន្ត្រីដែលទទួលខុសត្រូវខាងផ្នែកអគ្គិសនី ឬគោលនយោបាយអគ្គិសនីឱ្យបានសមស្រប ។ រដ្ឋមន្ត្រីទាំងនោះត្រូវជួបប្រជុំនៅពេលដែលយល់ថាចាំបាច់ ឬតាមការស្នើសុំរបស់ប្រធានគណៈកម្មការសម្របសម្រួលពាណិជ្ជកម្មថាមពលអគ្គិសនីក្នុងមហាអនុតំបន់មេគង្គ (RPTCC) ដែលនឹងត្រូវបង្កើតដោយអនុលោមតាមមាត្រាទី ៤-២ នៃកិច្ចព្រមព្រៀងនេះ ។

៤.២ បណ្តាភាគីត្រូវទទួលស្គាល់តម្រូវការចាំបាច់សំរាប់អង្គការជាន់ខ្ពស់ គឺគណៈកម្មាធិការសម្របសម្រួលពាណិជ្ជកម្មថាមពលអគ្គិសនីក្នុងមហាអនុតំបន់មេគង្គ (RPTCC) ដើម្បីសម្របសម្រួលយ៉ាងសកម្មឱ្យបានជោគជ័យដល់ការអនុវត្តន៍ពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់ និងជាតំណាងឱ្យបណ្តាប្រទេសដែលជាប់ទាក់ទងនឹងពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់ ។ បណ្តាភាគីត្រូវចាត់តាំងតំណាងជាតិរបស់ខ្លួនសំរាប់វេទិកាថាមពលអគ្គិសនីបច្ចុប្បន្ន ដើម្បីបង្កើតឡើងគណៈកម្មាធិការ RPTCC បណ្តោះអាសន្នទី ១ ដើម្បីអនុវត្តកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះ ។ គណៈកម្មាធិការ RPTCC នឹងរាយការណ៍ជូនសន្និសិទថ្នាក់រដ្ឋមន្ត្រី GMS និងរដ្ឋាភិបាលជាតិរៀង១ខ្លួន តាមរយៈរដ្ឋមន្ត្រីដែលមានចែងក្នុងមាត្រា៤.១ នៃកិច្ចព្រមព្រៀងនេះ ។ គណៈកម្មាធិការ RPTCC នឹងមានឯករាជ្យភាពក្នុងការគ្រប់គ្រងប្រតិបត្តិការរបស់ខ្លួនសំរាប់គោលបំណងនៃការសម្រេចបានទិសដៅដ៏ចំបងរបស់ខ្លួន ។ ក្រុមអ្នកជំនាញលើការតភ្ជាប់ និងពាណិជ្ជកម្មថាមពលអគ្គិសនីបច្ចុប្បន្នត្រូវផ្តល់ការគាំទ្របច្ចេកទេសដល់គណៈកម្មាធិការ RPTCC។

៤-៣ តួនាទីរបស់គណៈកម្មាធិការ RPTCC - មុខងារទី១របស់ RPTCC គឺកំណត់ឱ្យបានកាន់តែច្បាស់ នូវជំហានទី១ ក្នុងការបង្កើត និងការអនុវត្តន៍ការរៀបចំពាណិជ្ជកម្មតំបន់ដែលនឹងត្រូវដាក់ជូនបណ្តាភាគីដើម្បីអនុម័ត ។ ឯកសារនេះត្រូវរួមបញ្ចូលទាំងផែនការដើម្បីសម្រេចការងារដូចតទៅ :

ក) ផ្តល់ដល់បណ្តាភាគីសេចក្តីព្រាងចុងក្រោយនៃកិច្ចព្រមព្រៀងប្រតិបត្តិការពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់ PTOA ដែលនឹងត្រូវកំណត់ជាកំលាក់បទបញ្ជានៃពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់

ខ) ផ្តល់ដល់បណ្តាភាគីនូវអនុសាសន៍សំរាប់គោលនយោបាយទាំងមូល និងការគ្រប់គ្រងប្រចាំថ្ងៃនៃពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់ រួមបញ្ចូលទាំងអង្គភាពចាំបាច់សំរាប់ការសម្របសម្រួល

គ) បង្កើតគំនិតផ្តួចផ្តើមរយៈពេលខ្លី មធ្យម និងវែង ដែលត្រូវការចាំបាច់អនុវត្តលើមូលដ្ឋានអាទិភាពដើម្បីសម្រេចបានទិសដៅនៃការធ្វើពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់នៅក្នុងតារាងពេលវេលាជាកំលាក់មួយ និង

បកប្រែក្រៅផ្លូវការ

ឃ) រកឱ្យឃើញជំហានចាំបាច់ សំរាប់ការអនុវត្តន៍ពាណិជ្ជកម្មតំបន់ រួមទាំងមធ្យោបាយសំរាប់ហិរញ្ញប្បទាន ។

៤.៤ បណ្តាភាគីក៏ត្រូវអនុញ្ញាតិឱ្យអាជ្ញាធរ និង សហគ្រាសអគ្គិសនីជាតិដែលបានចាត់តាំង ដើម្បីចូលរួមក្នុងកិច្ចព្រមព្រៀងចាំបាច់ ដើម្បីបញ្ញត្តិការបង្កើត និង ប្រតិបត្តិការពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់ រួមទាំងកិច្ចព្រមព្រៀងប្រតិបត្តិការពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់ (PTOA) ដែលត្រូវដាក់ជូនគណៈកម្មាធិការ RPTCC ដើម្បីសម្រេច ។ បណ្តាភាគីត្រូវគាំទ្រ និង ជួយដល់អាជ្ញាធរ និង សហគ្រាសអគ្គិសនីជាតិដែលបានចាត់តាំងរៀង១ខ្លួន ក្នុងការអនុវត្តន៍ និងប្រតិបត្តិការកាតព្វកិច្ចរបស់ខ្លួន ក្នុងលក្ខខ័ណ្ឌដែលកិច្ចព្រមព្រៀងណាមួយបានចុះកិច្ចព្រមព្រៀងរវាងសហគ្រាសថាមពលអគ្គិសនីរៀង១ខ្លួន ស្របតាមកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះ និងអនុលោមតាមសេចក្តីថ្លែងការណ៍គោលនយោបាយ ។

## មាត្រា៥ : បណ្តាភាគីនៃកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល

៥.១ កិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះ បើកចំហរដល់ការចុះហត្ថលេខាដោយប្រទេសសមាជិករបស់ GMS ទាំងអស់ ។

៥.២ ការបញ្ចូលបន្ថែមបណ្តាប្រទេសមិនមែនជាសមាជិក GMS ត្រូវដាក់ពាក្យស្នើសុំសម្រេចទៅបណ្តាភាគី GMS ទាំងអស់នៃកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះ ។ លក្ខខ័ណ្ឌសំរាប់បញ្ចូលសមាជិកថ្មីនេះនឹងត្រូវធ្វើជាកិច្ចព្រមព្រៀងដោយឡែក ដែលនឹងត្រូវដាំផ្តែកភ្ជាប់មកជាមួយនៃកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះ ។

## មាត្រា៦ : ការដោះស្រាយវិវាទ

ភ្នាក់ងារដែលបានអនុញ្ញាតិឱ្យអនុវត្តកិច្ចព្រមព្រៀងនេះ ត្រូវស្វែងរកដំណោះស្រាយប្រកបដោយភាតរៈភាពរយៈការពិគ្រោះយោបល់ចំពោះភាពមិនស្របគ្នាណាមួយក្នុងការបកស្រាយ ឬការអនុវត្តន៍នៃកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះ ។ ក្នុងករណីដែលភ្នាក់ងារមានសិទ្ធិមិនអាចដោះស្រាយបញ្ហាណាមួយដោយភាតរៈបាន បញ្ហានេះត្រូវបញ្ជូនទៅបណ្តាភាគីដើម្បីដោះស្រាយ ។

## មាត្រា៧ : សច្ចានុម័ត និង ការចូលជាធរមាន

៧.១ កិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះត្រូវធ្វើសច្ចានុម័ត ឬយល់ព្រមដោយបណ្តាភាគីដោយអនុលោមតាមនិតិវិធីជាតិរៀង១ខ្លួន ។ បណ្តាភាគីត្រូវពិនិត្យមើល និង ធ្វើឱ្យបានរួសរាន់ការធ្វើសច្ចានុម័ត ឬ ដំណើរការសម្រេចយល់ព្រមនៅក្នុងអង្គការជាតិរៀង១ខ្លួន ។ ភាគីនីមួយៗត្រូវជូនដំណឹងអំពីការធ្វើសច្ចានុម័ត ឬការយល់ព្រមទៅបណ្តាភាគីផ្សេងទៀត ។

បកប្រែក្រៅផ្លូវការ

៧.២ កិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះ ត្រូវចូលជាធរមានរវាង និងក្នុងចំណោមភាគីដែលបានធ្វើសច្ចានុម័ត ឬ យល់ព្រមលើកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល នៅក្នុងកាលបរិច្ឆេទនៃការចេញឯកសារឧបករណ៍ទីបី នៃការធ្វើសច្ចានុម័ត ឬ ការយល់ព្រម ។

## មាត្រា៨ : ថេរវេលានៃកិច្ចព្រមព្រៀង

៨.១ កិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះនឹងនៅមានប្រសិទ្ធភាពរហូតដល់មានការកែសំរួល ឬការបញ្ចប់ដោយបណ្តាភាគី ។

## មាត្រា ៩ : ការដកខ្លួនចេញពីកិច្ចព្រមព្រៀង

៩.១ បណ្តាភាគីសង្ឃឹមថា នឹងបន្តកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់របស់ខ្លួន ។ ទោះជាយ៉ាងណាក៏ដោយ ភាគីណាមួយដោយបានផ្តល់រយៈពេលមួយឆ្នាំ ដើម្បីសរសេរកំណត់បង្ហាញដល់ភាគីផ្សេងទៀតសុំដកខ្លួនចេញពីកិច្ចព្រមព្រៀង IGA នេះ បន្ទាប់ពីរយៈពេលផុតកំណត់ ២ ឆ្នាំ គិតចាប់ពីថ្ងៃ ខែ ឆ្នាំ នៃការចូលជាធរមានរបស់កិច្ចព្រមព្រៀង ឬពេលណាមួយបន្ទាប់ ។ ការដកខ្លួនត្រូវមានប្រសិទ្ធភាពរយៈពេល ១ឆ្នាំ បន្ទាប់ពីពេលបានទទួលកំណត់បង្ហាញដោយភាគីផ្សេងទៀតក្នុងរយៈពេលនេះ ភាគីដែលបានដកខ្លួនចេញត្រូវបន្តគោរពតាមប្រការដែលមានចែងក្នុង IGA នេះ ។ ការដកខ្លួនចេញពី IGA នេះ នឹងមិនមានការប៉ះពាល់ដល់កិច្ចព្រមព្រៀង និងកិច្ចសន្យាទាំងឡាយដែលបានចុះហត្ថលេខាដោយផ្អែកលើមូលដ្ឋាននៃកិច្ចព្រមព្រៀងនេះ រហូតដល់មានការបញ្ចប់កិច្ចព្រមព្រៀងកិច្ចសន្យាទាំងនោះ ។

## ១០ : ទំនាក់ទំនងនឹងកិច្ចព្រមព្រៀងផ្សេងៗ

១០.១ កិច្ចព្រមព្រៀងជាមួយភាគីមិនជាសមាជិក GMS ទាំងអស់:

កិច្ចព្រមព្រៀង IGA នេះ មិនកំរិតដល់ភាគី GMS ណាមួយ ពីការចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មថាមពលអគ្គិសនីជាមួយបណ្តាភាគីមិនមែនជាសមាជិក GMS អោយតែកិច្ចព្រមព្រៀងទាំងនោះមិនបង្កើតឱ្យមានកាតព្វកិច្ចដល់ភាគី GMS ដែលមិនមែនជាសមាជិកនៃកិច្ចព្រមព្រៀងនោះ និងកិច្ចព្រមព្រៀងនោះមិនធ្វើឱ្យភាគី GMS រាំងស្ទះក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់នៃតំបន់ GMS ។

១០.២ កិច្ចព្រមព្រៀងដែលមានពីមុន :

ក) ការចុះនៃកិច្ចព្រមព្រៀង IGA នេះនឹងមិនធ្វើឱ្យរាំងស្ទះ កែប្រែ ឬផ្លាស់ប្តូរកិច្ចព្រមព្រៀងមុនណាមួយឡើយ រហូតដល់ពេលផុតកំណត់ ឬការបញ្ចប់កិច្ចសន្យា ឬកិច្ចព្រមព្រៀងនោះ ដោយស្របទៅតាមបញ្ញត្តិគោលរបស់វា លើកលែងតែបានកែប្រែ ឬបញ្ចប់ដោយមានការយល់ព្រមទៅវិញទៅមករវាងភាគីទាំងអស់នៃកិច្ចសន្យា ឬកិច្ចព្រម

បកប្រែក្រៅផ្លូវការ

ព្រៀងនោះ ។ កិច្ចព្រមព្រៀងនោះ នឹងមិនអាចពន្យាពេលឱ្យហួសកាលបរិច្ឆេទផុតកំណត់ដើមរបស់ខ្លួនឡើយ ហើយកិច្ចព្រមព្រៀងថ្មីទាំងឡាយត្រូវព្យាយាមធ្វើឱ្យស្របគ្នានឹងកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះ។

ខ) នៅពេលដែលកិច្ចព្រមព្រៀង IGA តំរូវមិនឱ្យមានការចាប់បង្ខំផ្លាស់ប្តូរ កែប្រែ ឬ បញ្ចប់កិច្ចព្រមព្រៀង ឬកិច្ចសន្យាដែលមានពីមុន បណ្តាភាគីនៃ IGA ត្រូវលើកទឹកចិត្តដល់ភាគីពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងពីមុនឱ្យអនុវត្តក្នុងកំរិតដែលអាចធ្វើទៅបាន គឺខិតខំដោយសុទ្ធចិត្តដើម្បីចរចារឡើងវិញលើលក្ខខណ្ឌណាដែលប៉ះពាល់ដល់ពាណិជ្ជកម្មតំបន់ឱ្យបានមុនថ្ងៃចាប់ផ្តើមដំណើរការពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់លើកដំបូង ។

១០.៣ កិច្ចព្រមព្រៀងតំបន់ផ្សេងៗ:

ក) បណ្តាភាគីសូមបញ្ជាក់ថា នឹងបន្តគោរពសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនទៅតាមកិច្ចព្រមព្រៀង ឬកតិកាសញ្ញាតំបន់ដែលកំពុងមានហើយដែលខ្លួនក៏ជាភាគីដែរ ។

ខ) បណ្តាភាគីដឹងហើយថា មានគំនិតផ្តួចផ្តើមខ្លះទាក់ទងទៅនឹងពាណិជ្ជកម្មតំបន់នៅក្នុង GMS ។ ដូច្នេះបណ្តាភាគីត្រូវកំណត់ការទទួលខុសត្រូវចំពោះគណៈកម្មាធិការ RPTCC ដើម្បីធានាការសម្របសម្រួលគំនិតផ្តួចផ្តើមទាំងអស់ដែលជំរុញឱ្យមានពាណិជ្ជកម្មតំបន់នៅក្នុងតំបន់ ដើម្បីជៀសវាងការជាន់គ្នានៃកិច្ចខិតខំប្រឹងប្រែង និងដើម្បីធ្វើឱ្យប្រសើរឡើងដល់ផលប្រយោជន៍នៃកិច្ចសហប្រតិបត្តិការ។

## មាត្រា ១១ : ការពិនិត្យកែសំរួល និង ការធ្វើវិសោធនកម្ម

១១.១ បញ្ញត្តិនៃកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះនឹងត្រូវពិនិត្យកែសំរួលក្នុងរយៈពេល ៥ឆ្នាំ ឬក៏ឆាប់ជាងតាមសំណើយ៉ាងតិចបំផុតស្មើនឹងមួយភាគបីនៃបណ្តាភាគី GMS និងអាចធ្វើវិសោធនកម្មបានតាមសំណើដោយមានការយល់ព្រមពីសំណាក់បណ្តាភាគីនៃកិច្ចព្រមព្រៀងនេះ។

## មាត្រា ១២: កិច្ចព្រមព្រៀងរួម

១២.១ កិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះជាការយល់ព្រមរួម ក្នុងចំណោមភាគីទាំងអស់ ។

ដើម្បីជាសក្ខីភាព អ្នកចុះហត្ថលេខាខាងក្រោម ដែលទទួលសិទ្ធិពេញលេញក្នុងនាមជាតំណាងរដ្ឋាភិបាលរៀងៗខ្លួនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះលើច្បាប់ដើមចំនួន ៦ ជាភាសាអង់គ្លេស។

បានធ្វើ និងចុះហត្ថលេខានៅភ្នំពេញ

នៅថ្ងៃទី ០៣ ខែ ខែវិច្ឆិកា ឆ្នាំ២០០២

ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

.......................................

ឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

បកប្រែក្រៅផ្លូវការ

ក្នុងនាមសាធារណៈរដ្ឋប្រជាមានិតចិន

-----------------------------------

ឯកឧត្តម យូ ហ្គង់ហ្សូ អនុរដ្ឋមន្ត្រី គណៈកម្មាធិការផែនការអភិវឌ្ឍន៍រដ្ឋ

ក្នុងនាមសាធារណៈរដ្ឋប្រជាមានិតឡាវ

-----------------------------------

ឯកឧត្តម សូមផុង ម៉ុងខុនវិឡាយ រដ្ឋមន្ត្រីទីស្តីការនាយករដ្ឋមន្ត្រី

ក្នុងនាមរដ្ឋាភិបាលសហព័ន្ធភូមា

-----------------------------------

ឯកឧត្តម ប្រិច ជេន ដាវីដ អាបែល រដ្ឋមន្ត្រី ប្រធានទីស្តីការ សន្តិភាព និងអភិវឌ្ឍន៍រដ្ឋ

ក្នុងនាមរដ្ឋាភិបាលព្រះរាជាណាចក្រថៃឡង់

...........................................................

ឯកឧត្តម ភុងធេប ធេបកាន់យ៉ាណា រដ្ឋមន្ត្រីថាមពល

ក្នុងនាមរដ្ឋាភិបាលនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម

-----------------------------------

ឯកឧត្តម វ៉ូ ហុង ហ៊្វុក រដ្ឋមន្ត្រីក្រសួងផែនការ និង ការវិនិយោគ

បកប្រែក្រៅផ្លូវការ

## ឧបសម្ព័ន្ធ ក

## សេចក្តីថ្លែងការណ៍គោលនយោបាយ ស្តីពីពាណិជ្ជកម្មថាមពលអគ្គិសនីក្នុងមហាអនុតំបន់មេគង្គ

សេចក្តីថ្លែងការណ៍គោលនយោបាយនេះ ( សេចក្តីថ្លែងការណ៍គោលនយោបាយ ) រៀបចំនៅភ្នំពេញ នៅថ្ងៃទី ២៨ ខែតុលា ឆ្នាំ ១៩៩៥។

រវាង:

សមាជិកមហាអនុតំបន់មេគង្គទាំងអស់